# សាររបស់ឯកឧត្តមហ៊ីដេហ៊ីសា ហូរីណូអ៊ុជិ
# ឯកអគ្គរាជទូតជប៉ុនប្រចាំកម្ពុជា ក្នុងឱកាសចំរើនព្រះជន្មគំរប់៨៣ព្រះវស្សា
# របស់ព្រះចៅអធិរាជអាគីហ៊ីតូ នៃប្រទេសជប៉ុន

ខ្ញុំមានក្តីសោមនស្សរីករាយ សូមផ្ញើសារជូនប្រជាជនកម្ពុជា ក្នុងពិធីចម្រើនព្រះជន្មព្រះករុណាព្រះចៅអធិរាជជប៉ុន។ ថ្ងៃនេះគឺជាថ្ងៃទី២៣ ខែធ្នូ ដែលព្រះករុណាព្រះចៅអធិរាជអាគីហ៊ីតូ មានព្រះជន្មាយុគម្រប់៨៣ព្រះវស្សា។

ខ្ញុំមានសេចក្តីសប្បាយរីករាយជំរាបជូនថា ព្រះករុណាព្រះចៅអធិរាជ និងអធិរាជនីទាំងពីរអង្គមានព្រះរាជសុខភាពល្អ និង បំពេញព្រះរាជកិច្ចជាផ្លូវការរបស់ព្រះអង្គយ៉ាងសកម្ម។

ឆ្នាំ២០១៦ មានព្រឹត្តិការណ៍ជាប្រវត្តិសាស្ត្រនៃទំនាក់ទំនងទ្វេភាគីរវាងជប៉ុន និងកម្ពុជា។ គឺជាការចាប់ផ្តើមជើងហោះហើរត្រង់ជាប្រចាំរវាងប្រទេសទាំងពីរ ដោយក្រុមហ៊ុនអាកាសចរណ៍ ANA ។ ខ្ញុំជឿជាក់ថាការហោះហើរត្រង់ទាំងនេះ នឹងធ្វើអោយប្រទេសជប៉ុនខិតមកកាន់តែជិតជាមួយប្រទេសកម្ពុជា និងជម្រុញការផ្លាស់ប្តូររវាងប្រជាជននៃប្រទេសទាំងពីរបន្ថែមទៀត។

ទោះបីជាមានត្រឹមតែរយៈពេលពីរខែ រាប់តាំងពីពេលខ្ញុំបានមកដល់ប្រទេស កម្ពុជាក៏ដោយ ប៉ុន្តែខ្ញុំមានការចាប់អារម្មណ៍នូវការអភិវឌ្ឍន៍ដ៏គួរអោយកត់សំគាល់របស់កម្ពុជា ព្រមទាំងរីករាយជាមួយការស្វាគមន៍ដ៏កក់ក្តៅរបស់ប្រជាជនកម្ពុជាចំពោះរូបខ្ញុំ។ កត្តានេះបានធ្វើអោយខ្ញុំប្តេជ្ញាបំពេញភារកិច្ចអោយ

អស់ពីលទ្ធភាពដើម្បីបន្តជម្រុញបន្ថែមនូវទំនាក់ទំនងរវាងជប៉ុននិងកម្ពុជា។

ក្នុងឱកាសពិធីចម្រើនព្រះជន្មាយុព្រះករុណាព្រះចៅអធិរាជ និងចូលឆ្នាំថ្មីខាងមុខនេះ ខ្ញុំសូមជូនពរអោយចំណងមិត្តភាពរវាងជប៉ុន និងកម្ពុជានៅតែបន្តជារៀងរហូត និងសូមអោយប្រជាជនកម្ពុជាទទួលបានតែសុខភាពល្អ និងសុខសុភមង្គល។